# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ វត្តខ្មែរកាណាដា ជុំវិញបញ្ហាកែប្រែអក្សសាស្ត្រខ្មែរ

**Website: www.hoksavann.org**

ថ្ងៃទី៩ តុលា ២០០៤

គ្រប់ជាតិសាសន៍ក្នុងលោកតែងមានអក្សរសាស្ត្រ គឺជាភាសានិយាយនិងភាសាសរសេរ សំរាប់ទាក់ទងគ្នាទៅវិញទៅមក និងសំរាប់ផ្ទុកមុខវិជ្ជាផ្សេងៗ។ យ៉ាងណាមិញ ប្រទេសកម្ពុជាក៏មានអក្សរសាស្ត្ររបស់ខ្លួនដ៏រុងរឿងជាច្រើនសតវត្សមកហើយ ។ បច្ចុប្បន្ននេះ ដោយសារតែប្រទេសកម្ពុជាមានវិបត្តិផ្ទៃក្នុងជាច្រើនទសវត្ស ពុំអាចរៀបចំអក្សរសាស្ត្ររបស់ខ្លួនឲ្យចំរើនលូតលាស់ឡើយ ។ មិនតែប៉ុណ្ណោះ នៅពេលដែលប្រទេសកម្ពុជាមានសន្តិភាពឡើងវិញ មានខ្មែរមួយក្រុមតូចបានលួចកែប្រែអក្សរសាស្ត្រខ្មែរ ផ្តែកអក្សរសរសេរជាច្រើនពាក្យ ដោយផ្អែកលើមូលដ្ឋានពុំសមហេតុផល ។ ធម្មតាអក្សរសាស្ត្រជាតិណាក៏ដូចជាតិណា ពុំអាចមានពាក្យគ្រប់គ្រាន់សំរាប់ប្រើការឡើយ តែងតែមានខ្ចីពីពាក្យនៃភាសាដទៃមកប្រើបន្ថែម ។ ដូចភាសាបារាំងនិងភាសាអង់គ្លេស មានខ្ចីពាក្យពីភាសាក្រិកនិងភាសាឡាតាំងជាច្រើន ។ ពាក្យកម្ចីទាំងនោះ គេរក្សាទុករូបរាងដើម គ្រាន់តែសំរួលសម្លេងឲ្យស្របតាមភាសាខ្លួនប៉ុណ្ណោះ ។ ដូចគ្នានេះដែរ ពាក្យខ្មែរពាក្យពីភាសាសំស្ក្រឹតនិងបាលីជាដើម ប៉ុន្តែបង្វែសម្លេងឲ្យស្របតាមសម្លេងភាសាខ្មែរ ។ ដើម្បីចេះភាសាខ្មែរច្បាស់លាស់ គេត្រូវតែសិក្សាភាសាសំស្ក្រឹតនិងភាសាបាលីផង ព្រោះមានពាក្យខ្លះមានឫសគល់ ចេញមកពីភាសាសំស្ក្រឹតនិងភាសាបាលី ។ ព្រះសង្ឃជាសមណសិស្សនិងសមណនិស្សិតសិក្សាភាសាបាលី តាំងពីពុទ្ធិកបឋមសិក្សា និងសិក្សាភាសាសំស្ក្រឹតតាំងពីពុទ្ធិកមធ្យមសិក្សា រហូតពុទ្ធិកឧត្តមសិក្សាផ្នែកបរិញ្ញាប័ត្រ ។ ប៉ុន្តែគួរឲ្យស្តាយ មានបញ្ញវ័ន្តខ្មែរខ្លះដែលមានចំណេះច្រើនខាងផ្លូវលោក ពុំបានដឹងជំរៅនៃភាសាខ្មែរ ហ៊ានកែប្រែពាក្យខ្មែរខ្លះដែលខ្មែរធ្លាប់ប្រើជាយូរមកហើយ ។ កាលមុនឆ្នាំ១៩៧០ មានបញ្ញវ័ន្តខ្មែរមានចំណេះខាងផ្លូវលោកម្នាក់ មានបំណងកែប្រែអក្សរសាស្ត្រខ្មែរ បញ្ញវ័ន្តម្នាក់នោះឈ្មោះ កេង-វ៉ាន់សាក់ ។ នៅពេលសម្តេចព្រះសង្ឃរាជជួន-ណាតប្រជុំអក្សរសាស្ត្រ ហើយគេយកមកចាក់ផ្សាយក្នុងវិទ្យុជាតិ សម្តេចព្រះសង្ឃរាជបានចោទទៅលើអ្នកដែលចង់កែប្រែអក្សរសាស្ត្រថា ជាមេក្រមីអក្សរសាស្ត្រ ។ អ្នកដែលសម្តេចព្រះសង្ឃរាជចោទនោះ គឺលោកកេង-វ៉ាន់សាក់នេះឯង ព្រោះលោកកេង-វ៉ាន់សាក់នេះធ្លាប់បានពន្យល់ព្រះសង្ឃសមណនិស្សិត ហើយពោលអំពីបំណងរបស់គាត់ក្នុងការកែប្រែនេះ ហើយបានសរសេរពាក្យខ្លះដែលគាត់កែប្រែប្រាប់សមណនិស្សិត ហើយសមណនិស្សិតយកមកទូលសម្តេចព្រះសង្ឃរាជជួន-ណាត ។ ដូច្នេះមេក្រមីអក្សរសាស្ត្រ គឺលោកកេង-វ៉ាន់សាក់នេះឯង ។ មានពាក្យខ្មែរខ្លះសរសេរតាមការពន្យល់របស់លោកកេង-វ៉ាន់សាក់ ដែលផ្ទុយពីវចនានុក្រមសម្តេចជួន-ណាត ។ អក្សរសាស្ត្រដែលមានការវិវឌ្ឍន៍នោះ គឺគេរក្សាទុកនូវពាក្យដែលមានហើយ គេពុំកែប្រែទេ ប៉ុន្តែគេបង្កើតពាក្យថ្មីៗទៀតដែលពុំទាន់មាន ឲ្យស្របតាមការចំរើនលូតលាស់នៃវិទ្យាសាស្ត្រ បច្ចេកសាស្ត្រ និងវិជ្ជាផ្សេងៗទៀត ។ ពាក្យខ្មែរដែលធ្លាប់សរសេរមកហើយ បានយល់ន័យរួចហើយ មិនត្រូវកែប្រែទេ ។ ពាក្យខ្មែរដែលខ្ចីមកពីភាសាសំស្ក្រឹតនិងបាលីមានន័យគ្រប់គ្រាន់នៅក្នុងពាក្យនោះ បើសរសេរជាខ្មែរសុទ្ធត្រូវប្រើសេចក្តីវែងទើបស្តាប់សេចក្តីបាន ។ មានកំហុសធំណាស់ ដែលគេព្រហើនកាត់ពាក្យខ្លះដែលចេញពីបាលីនិងសំស្ក្រឹត ហើយគេសរសេរអក្សរផ្សេងៗមានសម្លេងដូចគ្នា ។ ការសរសេរបែបនេះ ជាការបំបាត់ឫសគល់របស់ពាក្យ ហើយមានន័យផ្សេងពីពាក្យមុន ។ ថ្ងៃក្រោយបើគេស្រាវជ្រាវ ពុំដឹងថាពាក្យនោះចេញមកពីណា ជាពាក្យខ្មែរសុទ្ធឬចេញមកពីភាសាណាទេ ។ គេពុំត្រូវគិតថា ការសរសេរពាក្យខ្មែរសុទ្ធទើបជាអ្នកស្នេហាជាតិនោះទេ ព្រោះពាក្យខ្មែរខ្លះដែលចេញពីបាលីនិងសំស្ក្រឹតក្លាយជាភាសាខ្មែររួចទៅហើយ ។ មានអ្នកខ្លះវែកញែកអក្សរសាស្ត្រមានន័យទៅរកនយោបាយ ពុំវែកញែកទៅតាមការពិត តាមលក្ខណៈវិទ្យាសាស្ត្រទេ ។ ការបង្កើតពាក្យថ្មី បើរកពាក្យខ្មែរសុទ្ធពុំបានដោយត្រូវប្រើពាក្យវែងពេក ទើបគេក្រឡេកមើលភាសាបាលីនិងសំស្ក្រឹត អាចមានពាក្យខ្លីតែមានន័យគ្រប់គ្រាន់ ដោយគ្រាន់តែបង្វែសម្លេងឲ្យស្របតាមសម្លេងជាភាសាខ្មែរប៉ុណ្ណោះ ។ សម័យអាណានិគមនិយមបារាំងចង់កែប្រែតួអក្សរខ្មែរ ប៉ុន្តែពុំអាចធ្វើទៅបាន ដោយមានការប្រឆាំងយ៉ាងខ្លាំងក្លាពីព្រះសង្ឃខ្មែរ ។ សូមយល់ស្របតាមសេចក្តីប្រកាសរបស់ក្រសួងអប់រំដែលទុកវចនានុក្រមខ្មែរទាំងពីរភាគរបស់សម្តេចជួន-ណាត ក្នុងការប្រើប្រាស់ពាក្យខ្មែរ និងទុកជាមូលដ្ឋានក្នុងការបង្កើតពាក្យថ្មីៗទៀត ។ មួយទៀត ពាក្យខ្មែរខ្លះដែលបានកែប្រែនោះ ត្រូវតែត្រឡប់សរសេរដូចដើមវិញ គឺដូចសម័យមុនឆ្នាំ១៩៧០ សម័យសម្តេចសង្ឃរាជជួន-ណាតគង់នៅ ។ ត្រូវសរសេរ<ឬ>និង<ឮ>ពេញតួវិញ ពាក្យណាដែលត្រូវសរសេរអក្សរ<ឡ>ត្រូវសរសេរ<ឡ>វិញ ពាក្យណាដែលត្រូវសរសេរជាមួយអក្សរ<ណ> ត្រូវសរសេរជាមួយ<ណ>វិញជាដើម ។ នេះនិយាយអំពីការពុំយល់ស្របឲ្យកែប្រែពាក្យខ្លះរបស់ពាក្យខ្មែរដែលធ្លាប់សរសេរមកហើយ ។

ចំពោះការអានពាក្យខ្មែរខ្លះ ក៏មានកំហុសច្រើនណាស់ ។ សូមលើកយកពាក្យខ្លះ ដូចពាក្យថា «ទស្សនាវដ្តី> (ទសសៈណាវដ្តី) មិនត្រូវអានថា (ទសសៈនាវដ្តី)ទេ, ពាក្យថា<អត្តសញ្ញាណ (អត្តៈសញ៉ាណ) មិនត្រូវអានថា (អត្តៈសញ្ញញាណ)ទេ ព្រោះ<ស>ជាអឃោសៈ វាកាច់<ញា>ទៅជា<ញ៉ា> ។ ពាក្យ<បញ្ញវ័ន្ត>មិនត្រូវសរសេរ<បញ្ញាវ័ន្ត>ទេ ។ ពាក្យថា <អធិបតេយ្យ> តាមសម្តេចព្រះសង្ឃរាជជួន-ណាតមានព្រះថេរដីការថា មាន<ភាព>នៅក្នុងនោះហើយ មិនត្រូវដាក់<ភាព>ទៀតទេ ។ ពាក្យរាជស័ព្ទថា<ព្រះរោគ> មិនត្រូវបន្ថែម<រាជ>ថា<ព្រះរាជរោគ>ឡើយ ។ ពាក្យថា<ពោធិវង្ស> (ពោធិវាំង) មិនត្រូវអានថា <ពោធិវង្ស> (ពោធិវង់)ទេ ។ ត្រូវប្រើពាក្យថា<ជំនាញ> មិនត្រូវប្រើពាក្យថា<ចំណាន>ទេ ព្រោះពាក្យ<ចំណាន> ហៅក្លាយមកពីពាក្យ<ជំនាញ> ។ ប្រទេសកុម្មុយនិស្តមួយខ្មែរធ្លាប់ហៅថា <ប្រទេសគុយបា> មិនត្រូវហៅប្រទេស <យូបា> តាមភាសាអង់គ្លេសទេ ។ ខ្មែរមិនដែលនិយាយថា <ចុះហត្ថលេខាលើ>ទេ បើ<លើ>គឺ<លើអ្វីមួយ> ព្រោះ<លើ>ជានិបាតស័ព្ទ ពាក្យនេះឮតាមវិទ្យុបរទេសជាភាសាខ្មែរ ។ មានពាក្យច្រើនទៀតដែលនិយាយខុសសំនៀងភាសាខ្មែរ តែពេលនេះសូមសង្ខេបប៉ុណ្ណោះ អំពីកំហុសនៃការអាននេះ ។ សុភាសិតខ្មែរថា <សំដីសជាតិ មារយាទសព្វជ> <ភាសារលត់ជាតិរលាយ> ។ ដូច្នេះអក្សរសាស្ត្រជាវប្បធម៌មួយសំខាន់ណាស់សំរាប់

ជាតិនីមួយៗ ជាពិសេសសំរាប់ជាតិខ្មែរ ។ ប្រទេសមួយ បើវិស័យផ្សេងៗចំរើន អក្សរសាស្ត្រដែលជាសាខារបស់វប្បធម៌ក៏ចំរើន ទើបចាត់ទុកជាអារ្យប្រទេស ។ ខ្មែរគ្រប់រូបគប្បីរក្សាអក្សរសាស្ត្ររបស់ខ្លួនឲ្យគង់វង្ស និងរីកលូតលាស់ថែមទៀត កុំកែប្រែតាមតែយោបល់ផ្ទាល់ខ្លួនម្នាក់ៗ ។ ចំណែកបណ្ឌិត្យសភាខ្មែរ គប្បីជ្រើសរើសអ្នកចេះដឹងជ្រៅជ្រះខាងអក្សរសាស្ត្រជាសមាជិក ដើម្បីធ្វើឲ្យអក្សរសាស្ត្របានចំរើនលូតលាស់ ។